ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

លេខៈ ៤១ សសរ

# សេចក្ដីសម្រេច

## ស្ដីពី

## ការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំទីស្ដីការគណៈរដ្ឋមន្ត្រី

## ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៧ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរដ្ឋលេខាធិការនៃក្រសួងនិងរដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៨ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងអនុរដ្ឋលេខាធិការនៃក្រសួងនិងរដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្ដីការគណៈរដ្ឋមន្ត្រី

## សម្រេច

**ប្រការ១.-**

បែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំទីស្ដីការគណៈរដ្ឋមន្ត្រី មានដូចតទៅៈ

១. ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំរួមការងារក្នុងទីស្ដីការគណៈរដ្ឋមន្ត្រី ការងារបុគ្គលិក និងការងារផ្គត់ផ្គង់និងហិរញ្ញកិច្ច

២. ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី** រដ្ឋលេខាធិការប្រចាំការទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុករៀបចំកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កិច្ចប្រជុំអន្តរក្រសួង កិច្ចប្រជុំជំនាញបច្ចេកទេស ជួយសម្របសម្រួលការងារក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងទទួលចុះហត្ថលេខាលើសេចក្តីជូនដំណឹងចេញពីខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

៣. ឯកឧត្តម **សយ សុខា** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកជួយសម្របសម្រួលការងារគ្រឿងឥស្សរិយយស ក្រសួងផែនការ ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា និងការងារពិនិត្យតាមដានការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាល

៤. លោកជំទាវ **ឆាយ ឆ័ន់ឡឿន** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកជួយសម្របសម្រួលការងារក្រសួងការពារជាតិ ក្រសួងកិច្ចការនារី ការងាររាជកិច្ច និងតម្កល់ឯកសារជាតិ

៥. ឯកឧត្តម **ច័ន្ទ តានី** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកជួយសម្របសម្រួលការងារក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងការងារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

៦. ឯកឧត្តម **សុភ ផេង** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកជួយសម្របសម្រួលការងារក្រសួងយុត្តិធម៌ ការងារមេធាវីរាជរដ្ឋាភិបាល ការងារសិទ្ធិមនុស្ស និងការងារសភា

៧. ឯកឧត្តម **ជ្រា សុចិន្តា** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកជួយសម្របសម្រួលការងារក្រសួងធនធានទឹកនិងឧតុនិយម និងការងារគ្រប់គ្រងគ្រោះមហន្តរាយ

៨. ឯកឧត្តម **អ៊ុន វីរជាតិ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកជួយសម្របសម្រួលការងារ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងការងារជនជាតិដើមភាគតិច

៩. ឯកឧត្តម **តឹករ៉េត សំរេច** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកជួយសម្របសម្រួលការងារ ក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងក្រុមហ៊ុនអាកាសចរណ៍ជាតិអង្គរអែរ

១០. ឯកឧត្តម **ម៉ុន សំបូរ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកជួយសម្របសម្រួលការងារក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធម្មការ និងសាសនា

១១. ឯកឧត្តម **ឃឹម វុស្សីដា** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកជួយសម្របសម្រួលការងារ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ការរៀបចំពិធីនិងកិច្ចប្រជុំនានាក្នុងវិមានសន្តិភាព ការងារសន្តិសុខគោលដៅទីស្តីការគណៈរដ្ឋមន្ត្រីនិងទីស្តីការនាយករដ្ឋមន្ត្រី ការបញ្ជូនកងកម្លាំងកម្ពុជាចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងការងារអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន

១២. ឯកឧត្តម **ឈិត សុខុន** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកជួយសម្របសម្រួលការងារក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ក្រសួងទេសចរណ៍ និងក្រសួងបរិស្ថាន

១៣. ឯកឧត្តម **ខូយ ឃុនហ៊ួរ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកជួយសម្របសម្រួលការងារក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងរ៉ែនិងថាមពល ការងារក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ការងារសវនកម្ម និងការងារប្រឆាំងអំពើពុករលួយ

១៤. ឯកឧត្តម **ភឹមរ័ត្ន ទិសិដ្ឋ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកការងារវេទិកាសម្ព័ន្ធសង្គមស៊ីវិល និងជួយសម្របសម្រួលការងារ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ការងារអាស៊ាន ការងារសហជីព និងការងារអង្គការមហាជន

១៥. ឯកឧត្តម **ឆឹយ ឡើន** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកជួយសម្របសម្រួលការងារក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងព័ត៌មាន ការងារសរុបរៀបចំរបាយការណ៍ស្តីពីសកម្មភាពការងារទីស្តីការគណៈរដ្ឋមន្ត្រី និងរាជរដ្ឋាភិបាល រៀបចំឯកសារគាំទ្រកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី រៀបចំសេចក្តីជូនដំណឹងស្តីពីលទ្ធផលនៃកិច្ចប្រជុំគណៈរដ្ឋមន្ត្រី ការងាររៀបចំឯកសារអេឡិចត្រូនិកនិងព័ត៌មានវិទ្យា សារជូនពរនានា ការងារច្រកទ្វារកំពង់ផែសមុទ្រ ច្រកទ្វារអន្តរជាតិនិងច្រកទ្វារព្រំដែន និងជួយសម្របសម្រួលចង្កោមការងាររបស់ឯកឧត្តម **ប៊ុន សំបូរ**

១៦. ឯកឧត្តម **ប្រាក់ ផល្លា** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស

១៧. ឯកឧត្តម **ហែម គ្រាញ់ឥន្ទ្រនី** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជួយសម្របសម្រួលចង្កោមការងាររបស់ឯកឧត្តម **ច័ន្ទ តានី**

១៨. ឯកឧត្តម **ឈួន សុធី** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជួយសម្របសម្រួលចង្កោមការងាររបស់ឯកឧត្តម **ឈិត សុខុន**

១៩. ឯកឧត្តម **ឡៀន ម៉ៅ** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជួយសម្របសម្រួលការងារគ្រឿងឥស្សរិយយស

២០. ឯកឧត្តម **ឡេង សេង** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជួយសម្របសម្រួលចង្កោមការងាររបស់ឯកឧត្តម **តឹករ៉េត សំរេច**

២១. ឯកឧត្តម **ស៊ៀង ឈុនទ្រី** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជួយសម្របសម្រួលចង្កោមការងាររបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

២២. ឯកឧត្តម **ជាម សន្តារតន៍** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជួយសម្របសម្រួលការងារក្រសួងមុខងារសាធារណៈ និងការងារបុគ្គលិក

២៣. ឯកឧត្តម **ម្ញូន លឹមហេង** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជួយសម្របសម្រួលការងារផ្គត់ផ្គង់និងហិរញ្ញកិច្ច

២៤. លោកជំទាវ **មាសសាឯម ដានី** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជួយសម្របសម្រួលចង្កោមការងាររបស់លោកជំទាវ ឆាយ វ៉ាន់នឿន

២៥. ឯកឧត្តម **អ៊ុន ម៉ុណ្ណារ៉ា** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជួយសម្របសម្រួលចង្កោមការងារឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ីង ថូរ៉ាក់ស៊ី

២៦. ឯកឧត្តម **ឈឹម សៅគី** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជួយសម្របសម្រួលចង្កោមការងាររបស់ឯកឧត្តម សយ សុខា

២៧. ឯកឧត្តម **ឃុន ឋិនគេន** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជួយសម្របសម្រួលការងាររដ្ឋបាល និងពិធីការ

២៨. ឯកឧត្តម **អ៊ឹម ស៊ីថុល** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជួយសម្របសម្រួលការងារក្រុមប្រឹក្សាអ្នកច្បាប់

២៩. ឯកឧត្តម **ម៉ាង នែណាំ** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជួយសម្របសម្រួលចង្កោមការងាររបស់ឯកឧត្តម ខូយ យុនហ៊្សរ

៣០. ឯកឧត្តម **ឈួន ឆាម** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជួយសម្របសម្រួលកិច្ចការផ្ទៃក្នុង និងជួយការងារប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ

៣១. លោកជំទាវ **ឧុង សុគន្ធ** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជួយសម្របសម្រួលការងារផ្គត់ផ្គង់និងហិរញ្ញកិច្ច

៣២. ឯកឧត្តម **អាន ដាលី** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជួយសម្របសម្រួលចង្កោមការងាររបស់ឯកឧត្តម សុក ផេង

៣៣. ឯកឧត្តម **នែម ពេត** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជួយសម្របសម្រួលចង្កោមការងាររបស់ឯកឧត្តម ជ្រា សុចិន្តា

៣៤. ឯកឧត្តម **សេង ទៀង** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជួយសម្របសម្រួលការងារផ្គត់ផ្គង់និងហិរញ្ញកិច្ច

៣៥. ឯកឧត្តម **ដួង តារា** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស

៣៦. ឯកឧត្តម **ស ចាន់ធី** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជួយសម្របសម្រួលចង្កោមការងាររបស់ឯកឧត្តម ឃឹម វស្សីដា

៣៧. ឯកឧត្តម **គង់ គោត** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស

៣៨. ឯកឧត្តម **ចាន់ សុខុម** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស

៣៩. ឯកឧត្តម **សេត មូហាំម៉ាត់ស៊ីស** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជួយសម្របសម្រួលចង្កោមការងាររបស់ឯកឧត្តម អ៊ីន វីរជាតិ ។

**ប្រការ២.-**

រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រីត្រូវទទួលអនុវត្តការងារ ឬបេសកកម្មមួយចំនួនទៀតដែលឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីប្រគល់ជូន។

**ប្រការ៣.-**

ការបែងចែកភារកិច្ចនៅក្នុងប្រការ១ខាងលើ អាចធ្វើការកែសម្រួលបានក្នុងករណីចាំបាច់។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

ឯកឧត្តម និងលោកជំទាវដែលមានឈ្មោះដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ កញ្ញា ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

**កន្លែងទទួល:**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាព អគ្គនាយកដ្ឋាន និងនាយកដ្ឋានចំណុះទីស្តីការគណៈរដ្ឋមន្ត្រី
- ដូចប្រការ ៥ " **ដើម្បីអនុវត្ត**"
- ឯកសារ-កាលប្បវត្តិ